# កម្ពុជាក្រោម

ព្រឹត្តិបត្រចេញផ្សាយជារៀងរាល់ខែដោយសហព័ន្ធខ្មែរកម្ពុជាក្រោម

លេខ ២២ ឆ្នាំទី ០២ - ខែតុលា គ.ស. ២០០៥ - ព.ស. ២៥៤៩ - N0 22,October 2005

## សុន្ទរកថារបស់លោក ថៅ រៀប ប្រធានសភាព្រឹទ្ធាចារ្យសហព័ន្ធខ្មែរកម្ពុជាក្រោម

### ក្នុងឱកាសបើកទូរសន្និបាត កាលពីថ្ងៃអាទិត្យ ទី ២ តុលា ២០០៥



លោក ថៅ រៀប ប្រធាន សភា ព្រឹទ្ធាចារ្យ សហព័ន្ធ ខ្មែរកម្ពុជា ក្រោម

ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ !

ជនរួមជាតិទាំងឡាយជាទីគោរព !

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ តាំងនាមថ្នាក់ដឹកនាំ និងសមាជិក សមាជិកាសហព័ន្ធខ្មែរកម្ពុជាក្រោម ក្នុងនាមប្រធានសភាព្រឹទ្ធាចារ្យសហព័ន្ធខ្មែរកម្ពុជាក្រោម និងក្នុងនាមខ្ញុំបាទផ្ទាល់ សូមស្វាគមន៍ និងសូមអរព្រះគុណ និងអរគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រះវត្តមាន និងវត្តមានរបស់ព្រះតេជគុណ និងបងប្អូនជនរួមជាតិ នៅក្នុងអង្គទូរសន្និបាតនេះ ។

ដូចបងប្អូនជ្រាបស្រាប់ហើយថា សព្វថ្ងៃនេះ រដ្ឋអំណាចកុម្មុយនិស្តយួន នៅតែអនុវត្តផែនការបំបាត់ជាតិសាសន៍ខ្មែរជាបន្ត ។ គេបានប្រើគ្រប់មធ្យោបាយ មានទាំងធម៌ក្តៅផងត្រជាក់ផង ជាពិសេសថ្មីៗ នេះ គេបានបញ្ចុះបញ្ចូលថ្នាក់ដឹកនាំព្រះសង្ឃ និងបញ្ញវ័ន្តនៅក្នុងស្រុក តាមរយៈផ្តល់លាភសក្ការៈ និង បុណ្យស័ក្តិបន្តិចបន្តួច ។ ចំពោះព្រះតេជគុណ ឬបញ្ញាវ័ន្តណា ដែលពិបាកបញ្ចុះបញ្ចូល គេបំភិតបំភ័យឲ្យរត់ចោលស្រុក ឬ ចាប់ចងដាក់ពន្ធនាគារ ដូចករណីព្រះភិក្ខុ លី ភោ ជាដើម ។

ស្ថិតក្នុងកាលៈទេសៈនេះ សហព័ន្ធខ្មែរកម្ពុជាក្រោម ប្រើប្រាស់ ច្បាប់អន្តរជាតិ និង ប្រកាន់ខ្ជាប់យកធម៌អហិង្សា ស្របតាមមាគ៌ាព្រះពុទ្ធសាសនា ក្នុងការស្វែងរកយុត្តិធម៌ ជូនជនរួមជាតិយើង ដែលកំពុងរងទុក្ខវេទនា និងរងការចោទប្រកាន់ស្រេចតែអំពើចិត្ត ពីសំណាក់ អាជ្ញាធរកុម្មុយនិស្តយួន ។

ដើម្បីលាតត្រដាងនូវពុតត្បុតរបស់យួន ក្នុងយុទ្ធសាស្ត្រលុបបំបាត់ជាតិសាសន៍ខ្មែរ ក្នុងនោះមានការតែបន្លំប្រពៃណីទំនៀមទម្លាប់ កែច្នៃប្រវត្តិសាស្ត្រ តាមទិសដៅបន្ថោកបន្ទាបព្រះរាជា និងប្រជារាស្ត្រខ្មែរ សហព័ន្ធខ្មែរកម្ពុជាក្រោម នឹងបង្កើតក្រុមស្រាវជ្រាវប្រវត្តិសាស្ត្រ ចងក្រងឯកសារប្រកបដោយលក្ខណៈសត្យានុម័ត ។ យើងពុំចាំបាច់ឈ្លោះប្រកែកជាមួយយួនក្នុងរឿងនេះទេ ប៉ុន្តែភារកិច្ចរបស់យើងត្រូវធ្វើឲ្យជនរួមជាតិ និងសហគមន៍អន្តរជាតិយល់កាន់តែច្បាស់អំពីទឹកដី និងប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមយើង ។

ព្រះសង្ឃគ្រប់ព្រះអង្គ ជាទីសក្ការៈ បងប្អូនជនរួមជាតិជាទីគោរពស្នេហា !

មកដល់សតវត្សរ៍ទី ២១ នេះហើយ យួននៅតែប្រើកលល្បិច មិនទាន់ទទួលស្គាល់ធាតុពិតនៃប្រវត្តិសាស្ត្រទេ ចូរប្រយ័ត្ន កុំបណ្តោយខ្លួនឲ្យធ្លាក់ចូលក្នុងអន្ទាក់យួន ។

ជាទីបញ្ចប់ ខ្ញុំសូមបួងសួងដល់វត្ថុសក្តិសិទ្ធក្នុងលោកមេត្តាជួយប្រោសប្រទានដល់ជនរួមជាតិខ្មែរកម្ពុជាក្រោម និងសូមឲ្យបងប្អូនជនរួមជាតិ ដែលបានចូលរួមទូរសន្និបាតនេះជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ប្រការ ៕

សូមអរព្រះគុណ និងសូមអរគុណ !

## មាតិការឿង

-សុន្ទរកថារបស់លោក ថៅ រៀប.......................១
-ចលនាតស៊ូមួយ គោលការណ៍មួយ................២
-អាជ្ញាធរយួនបង្ខំឲ្យលុបឈ្មោះ.......................៣
-វត្តទាំង ២២ ក្នុងស្រុកកំពង់ស្ពាន...................៣
-អគ្គីភ័យបំផ្លាញផ្ទះសម្បែង............................៥
-ទូកង៉និស្សិតខ្មែរក្រោមលេខ ១.......................៦
-សម្ព័ន្ធសមណនិស្សិត ....................................៧
-ខ្មែរក្រោមនៅជីកាហ្គោ....................................៨
-សំណាកព្រះបាទជ័យវរ្ម័នទី ៧.....................១១
-កំណាព្យ ខ្ញុំជាប់គុកហើយ, ស្រណោះ.........១២
-រឿងកម្ពុជាក្រោមគឺជារឿងពិត...................១៣

# ចលនាតស៊ូមួយ គោលការណ៍មួយ

ខ្មែរក្រោមបានរស់នៅជាមួយយួន ស្គាល់រសជាតិជីវិតជូរចត់ជាមួយយួន ទទួលរងការឈឺចាប់កាប់សម្លាប់តពូជ ក៏ដោយស្នាដៃយួន និងទទួលស្គាល់ថា យួនមានល្បិចកិច្ចកលគ្រប់ជំពូក ។ យួនចេះប្រើល្បិចបោសអង្អែលលួងលោមដើម្បីសម្លាប់ខ្មែរ និយាយរួម គឺប្រល័យពូជសាសន៍ខ្មែរ ដើម្បីយកទឹកដីឲ្យពលរដ្ឋយួនរស់នៅយ៉ាងស្រួល និងទូលំទូលាយ ។

ខ្មែរក្រោមក្នុងស្រុករំពឹងបងប្អូនខ្មែរក្រោមនៅក្រៅស្រុករួមទាំងនៅព្រះរាជាណាចក្រកម្ពុជាផង ដើម្បីពាំនាំយកនូវរឿងរ៉ាវសោកនាដកម្ម ជីវិតរស់រាល់ថ្ងៃដ៏ក្រៀមក្រំឥតន័យ គ្មានតម្លៃជាមនុស្ស ដោយការជិះជាន់របស់យួនគ្រប់ជំនាន់ គ្រប់របបដឹកនាំនោះ យកទៅលាតត្រដាងប្តឹងទៅអន្តរជាតិ ។ តើបងប្អូនខ្មែរក្រោមរំពឹងថា យួននឹងប្តូរនូវចរិតរបស់វាដែរឬទេ ? ខ្មែរក្រោមណាក៏ឆ្លើយនូវសំណួរនេះដោយមិនចាំបាច់គិតដែរ

ដោយសារអ្វីទៅ ? គឺដោយសារយើងមានឈាមជ័រជាខ្មែរ យើងស្គាល់ច្បាស់ពុតយួន ។ ខ្មែរក្រោមបានបំរើយួនគ្រប់របប គ្រប់ជំនាន់ គ្រប់នយោបាយ បានចាញ់បោកយួន ប្រើដៃខ្មែរសម្លាប់ខ្មែរ ឯយួនចំណេញគ្មានថ្ងៃខាតម្តងណាឡើយ ។ ខ្មែរក្រោមបានរស់នៅ និងកំពុងតែរស់នៅក្រោមនឹមអាណានិគមរបស់យួន ហើយក្រុងហាណូយនៅតែបន្តល្បិចល្បែងនេះ រហូតដល់យួនរស់នៅទីណាក៏បាននៅតណ្ហាចិន ។

ដើម្បីទប់ទល់នឹងល្បិចទាំងនេះ គឺមានតែសាមគ្គីធម៌ដែលខ្មែរក្រោមបានទន្ទេញចាំមាត់នេះទេ ត្រូវតែអនុវត្តគ្រប់វិនាទី ត្រូវតែលះបង់នូវមេរោគយួន គឺមានះរឹងរូស ការបំរើយួនឬក៏ស្នេហាជាតិខ្វះសតិសម្បជញ្ញៈ... ដែលសុទ្ធតែជាកត្តាបរាជ័យ ។ ខ្មែរក្រោមបានរិះរកគ្រប់មធ្យោបាយទាំងអស់ ទោះជាបំរើយួនក៏ដោយ ឲ្យតែមានប្រយោជន៍ដល់ខ្មែរក្រោម ។ នេះដោយសារស្រលាញ់អាណិតជាតិ ទើបខិតខំបង្កើតចលនាគ្រប់បែបយ៉ាងដើម្បីជាតិ ទោះស្លាប់ក៏មិនគិតដល់ជីវិតខ្លួន ឬ គ្រួសារឡើយ ។

តើខ្មែរក្រោមទទួលបានលទ្ធផលឬទេ អំពីការតស៊ូដោយឯកោ មានះ ហិង្សា មិនខ្លាចស្លាប់ ដើម្បីសង្គ្រោះជាតិ សង្គ្រោះខ្មែរក្រោម ដើម្បីកម្ពុជាក្រោម បានតាមបំណងបុព្វបុរសយើង តាមសេចក្តីត្រូវការរបស់ខ្មែរក្រោមយើង ? ខ្មែរក្រោមគ្រប់ៗ រូបគប្បីទទួលស្គាល់ និងយល់ដឹងនូវទុក្ខធុរៈជាតិ ពេលដែលជាតិត្រូវការ ។ ពេលនេះ កម្ពុជាក្រោមត្រូវការកម្លាំងសាមគ្គីជាតិ ត្រូវការអ្នកក្លាហានតស៊ូពិត ៗ ។ ដូច្នេះ ខ្មែរក្រោមត្រូវតែបន្តយុទ្ធសាស្ត្រតស៊ូ គឺតស៊ូខ្មែរក្រោម តស៊ូអង្គការមួយ គោលដៅមួយ ប្រយោជន៍តែមួយ និងអ្នកទទួលផលតែមួយ គឺខ្មែរក្រោម ។ សហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក បានឈានមកដល់វេទិកាអន្តរជាតិ ហើយសហព័ន្ធមានលទ្ធភាព និងសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំតស៊ូផ្លូវច្បាប់លើឆាកអន្តរជាតិ និងទទួលការគាំទ្រពីគ្រប់មជ្ឈដ្ឋាន ។

ដូច្នេះ ដើម្បីឲ្យខ្មែរក្រោមមានសេរីភាព ដើម្បីឲ្យខ្មែរក្រោមរួចផុតពីអាណានិគមយួន គឺអាស្រ័យលើខ្មែរក្រោមគ្រប់ស្រទាប់ អាស្រ័យលើទឹកចិត្តខ្មែរក្រោម អាស្រ័យលើការលះបង់របស់ខ្មែរក្រោម និងអាស្រ័យលើការរួបរួមរបស់ខ្មែរក្រោមទាំងអស់គ្នា ខ្មែរកម្ពុជាក្រោមត្រូវការតែចលនាមួយគត់ ដើម្បីការពារការជ្រៀតចូលរបស់យួន ល្បិចយួន គំនិតយួន រោគយួន ។ សហព័ន្ធខ្មែរក្រោមពិភពលោក សូមធ្វើការអំពាវនាវដល់ជនរួមឈាមគ្រប់ទិសទី ទាំងនៅក្នុងស្រុកក្រៅស្រុក សូមមេត្តាគាំទ្រសហព័ន្ធឈរលើជំហរសាមគ្គីជាតិ និងស្រលាញ់ជាតិ ។

"តស៊ូដោយឯកោ មានះ រើរវាយ ជាចំណីទិព្វរបស់យួន" ៕

ចាច់ ងុក ចាច់

និពន្ធនាយក ៖ **ចាច់ ចន្ធូ** ផ្សព្វផ្សាយ ៖ **សឺន រតនៈ, សឺន ច័ន្ទ**
ឯកសារ PDF មាននៅក្នុងគេហទំព័រ www.khmerkrom.net

# អាជ្ញាធរយួន បង្ខំឱ្យលុបឈ្មោះសប្បុរសជននៅបរទេស

ថ្មី ៗ នេះ វត្តដៃតាប៉ាយ ដែលស្ថិតក្នុងឃុំដៃតាប៉ាយ ស្រុកជ្រោយញរ ខេត្តឃ្លាំង ត្រូវបានអាជ្ញាធរយួន ស្រុកជ្រោយញរ បង្ខំឲ្យលុបឈ្មោះសប្បុរសជន ដែលបានចាប់មគ្គផលក្នុងការកសាងរបងវត្ត និងព្រះវិហារ ដែលពុទ្ធបរិស័ទបានសរសេរភ្ជាប់លើជញ្ជាំងរបង និងលើផ្ដែរនៃតារាងកសាងព្រះវិហារ ។

វត្តដៃតាប៉ាយ ស្ថិតក្នុងឃុំដៃតាប៉ាយ ស្រុកជ្រោយញរ (យួនហៅវិញចូវ) ខេត្តឃ្លាំង និងមានចម្ងាយប្រមាណ ១៥ គីឡូម៉ែត្រ ខាងកើតផ្សារជ្រោយញរវត្តនេះ ត្រូវបានកសាងឡើងក្នុង គ.ស. ១៩៧៣ ។ លោកតាម្នាក់ស្នាក់ក្នុងវត្ត បានឲ្យដឹងថា វត្តដៃតាប៉ាយជាវត្តថ្មី ហេតុនេះហើយបានជាមានការខ្វះខាតសេនាសនៈច្រើន ហើយសព្វថ្ងៃកំពុងដំណើរការកសាងព្រះវិហារ ការកសាងទាំងនេះសោត ថវិកាមួយផ្នែកធំ គឺបានមកដោយអាស្រ័យទឹកចិត្តសប្បុរសពុទ្ធបរិស័ទខ្មែរនៅបរទេស តែគួរឲ្យស្ដាយ ពេលនេះរដ្ឋអំណាចបានបង្គាប់ឲ្យព្រះសង្ឃ និងគណៈកម្មការវត្តលុបឈ្មោះសប្បុរសជនសំខាន់ ៗ ខ្លះ ចេញពីតារាងចូលកុសលកសាងព្រះវិហារនោះចេញ ក្នុងនោះមាននាមថ្នាក់ដឹកនាំខ្មែរកម្ពុជាក្រោម គឺលោក ថាច់ ង៉ុក ថាច់ អតីតប្រធានព្រឹត្តិបត្រសហព័ន្ធខ្មែរកម្ពុជាក្រោមជាដើម ។

ព្រះធម្មាចារ្យ ១ ព្រះអង្គ គង់ក្នុងវត្តដៃតាប៉ាយនេះដែរ ព្រះអង្គបានបញ្ជាក់ពីមូលហេតុនៃការលុបឈ្មោះនោះ ដូច្នេះ ៖ គេបញ្ជាឲ្យលុប ហើយគេគំរាមបន្ថែមថា បើនរណាមួយហ៊ានចចេសទទឹងនឹងបញ្ជានេះ អ្នកនោះឯងនឹងត្រូវទទួលទោសចំពោះការរួមគំនិតនឹងក្រុមខ្មែរក្រោម ប្រឆាំងនឹងរដ្ឋអំណាចយួន ឬ ក្បត់ជាតិ ។ ព្រះអង្គបញ្ជាក់ទៀតថា គេឲ្យលុបនាមសប្បុរជនក្រៅប្រទេសចេញ គឺសំដៅយកតែតស្សូរៈជនខ្មែរក្រោម អ្នកស្នេហាជាតិ អ្នកនយោបាយសំខាន់ ៗ តែប៉ុណ្ណោះ ឯសប្បុរជនសាមញ្ញ គេមិនបង្ខំឲ្យលុបចេញនោះទេ ហើយមិនត្រឹមតែវត្តរបស់ព្រះអង្គមួយនោះទេ ដែលគេបង្ខំឲ្យធ្វើដូច្នេះ គឺវត្តខ្មែរទាំងអស់ទូទាំងខេត្តឃ្លាំងតែម្ដង ដូចជាករណីវត្តដើមត្នោត ស្ថិតនៅក្នុងស្រុកជ្រោយញរដែរ ដែលបានធ្វើបុណ្យបញ្ចុះសីមាកាលពីថ្ងៃទី ១២-១៣ មីនា កន្លងទៅ គឺមុននឹងធ្វើបុណ្យគេបញ្ជាឲ្យលុបពាក្យថា USA, CANADA និង AUSTRALY ចេញសិន ទើបគេអនុញ្ញាតិឲ្យធ្វើបុណ្យ ។

ចំណែកសមណនិស្សិត សឺន ភីរិទ្ធិ ជាសមណនិស្សិតនៅសាលាបាលីខេត្តឃ្លាំង ព្រះអង្គបានបញ្ចេញគំនិតថា "យួនគេធ្វើនេះ គឺគេចង់បំបាត់មិនឲ្យមានខ្មែរអ្នកស្នេហាជាតិ ស្នេហាយុត្តិធម៌នោះឡើយ ។ ទន្ទឹមនឹងនេះដែរ ពុទ្ធបរិស័ទចំណុះជើងវត្តដៃតាប៉ាយទាំងមូល បានលើកម្រាមដៃដប់ អំពាវនាវដល់ពុទ្ធបរិស័ទ សប្បុរសជននៅក្នុងប្រទេស ពិសេសបងប្អូនញាតិញោមនៅក្រៅប្រទេស សូមជួយឧបត្ថម្ភដល់ការកសាងវត្តដៃតាប៉ាយ ក៏ដូចជាវត្តខ្មែរនៅស្រុកក្រោមបន្ថែមទៀត សំខាន់គឺវត្តដៃតាប៉ាយនេះហើយ ខ្វះខាតជាងវត្តនានា ព្រោះពុទ្ធបរិស័ទចំណុះជើងវត្ត រងជម្ងឺពិការភ្នែកច្រើនណាស់ ដូច្នេះគឺសង្ឃឹមតែបងប្អូននៅក្រៅប្រទេសប៉ុណ្ណោះ ដែលអាចយឹតយោងសណ្ដោងកសាងការពារវត្តអារាមយើងបាន ៕

VOKK

# វត្តទាំង ២២ ក្នុងស្រុកកំពង់ស្ពាន ត្រូវរងការព្រមាន




អាជ្ញាធរស្រុកកំពង់ស្ពាន (យួនប្ដូរហៅថាស្រុកកូរកែ) ខេត្តព្រះត្រពាំង កាលពីថ្ងៃទី ០៦ កញ្ញា កន្លងទៅ បានកោះហៅព្រះចៅអធិការ និងគណៈកម្មការវត្តទាំង ២២ ទូទាំងស្រុក ឲ្យចូលខ្លួនទៅសាលាស្រុក ដើម្បីទទួលការស្ដីបន្ទោសពីបទមិនបានរារាំងព្រះសង្ឃដែលបានភៀសខ្លួនទៅកម្ពុជា តែព្រះចៅអធិការខ្លះ បានប្រាប់មនុស្សជំនិតរបស់ខ្លួនថា "បើរដ្ឋាភិបាលគោរពសិទ្ធិមនុស្សបានត្រឹមត្រូវ នឹងគ្មានការរត់ភៀសខ្លួននោះទេ" ។

ស្រុកកំពង់ស្ពាន មានវត្តចំនួន ២២ ជាស្រុកជាប់ចំណាត់ថ្នាក់លេខ ៣ ក្នុងចំណោមស្រុកទាំង ៨ នៃខេត្តព្រះត្រពាំង ដែលមានខ្មែររស់នៅ ឯវត្តស្រុកជាប់ចំណាត់ថ្នាក់លេខ

២ នោះ គឺស្រុកផ្ទោរដាច់ មាន ២៣ វត្ត លេខ ១ គឺស្រុកចូវ មាន ២៤ វត្ត ហើយបើគិតទូទាំងខេត្ត ក្នុងចំណោមស្រុកទាំង ៨ គឺមាន ១៤១ វត្ត ហើយស្រុកដែលមានកំណើនព្រះសង្ឃ ភៀសខ្លួនទៅព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ ២០០៥ នោះ គឺ ស្រុកកំពង់ស្ពាន ។

ព្រះចៅអធិការវត្តមួយព្រះអង្គក្នុងចំណោមមន្ត្រីសង្ឃ និងគណៈកម្មការ ដែលត្រូវកោះហៅចូលរួមប្រជុំទទួលការស្តីបន្ទោសនោះ មានថេរដីកាឲ្យដឹងថា នៅថ្ងៃទី ០៦ កញ្ញា ការិយាល័យធម្មការ និងនគរបាលស្រុកកំពង់ស្ពាន បានកោះហៅមន្ត្រីសង្ឃ និងគណៈកម្មការតាមវត្តទៅប្រជុំនេះ គឺគេឲ្យតាមវត្តនីមួយ ៗ ត្រូវអនុវត្តឲ្យបានម៉ត់ចត់នូវរបាយការណ៍ប្រចាំខែឡើងទៅមន្ត្រីសង្ឃថ្នាក់ស្រុក ៖

ទី១-ការគ្រប់គ្រងស្ថិតិចំនួនព្រះសង្ឃ និងប្រជាជនចេញចូល និងស្នាក់នៅអចិន្ត្រៃយ៍ ។

ទី២-ត្រូវតាមដានមើល ព្រះសង្ឃដែលទៅកម្ពុជា តើទៅធ្វើអ្វីខ្លះ ? នៅកន្លែងណា? វត្តណា ?

ទី៣-លទ្ធផលដែលបានអូសទាញព្រះសង្ឃ និងពុទ្ធបរិស័ទដែលភៀសខ្លួនទៅកម្ពុជាថ្មី ៗ នេះឲ្យត្រឡប់មកវិញ តើបានផលយ៉ាងណាខ្លះ ? ហើយប្រការពិសេសមួយទៀត គឺពួកគេបានបង្ខំឲ្យមន្ត្រីសង្ឃ ឬ គណៈកម្មការវត្តត្រូវរាយការណ៍ជាបន្ទាន់ដល់សមត្ថកិច្ចមូលដ្ឋាននូវព្រឹត្តិការណ៍សំខាន់ ៗ ដូចជាមានអ្នកចំឡែកចូលស្រុក ឬ មានជនណាចង់បង្កើតជាក្រុម ជាចលនាអ្វីមួយ ឬក៏នាំគ្នាចង់រត់ភៀសខ្លួនទៅកម្ពុជា ឬមួយមានជនណានាំមកនូវឯកសារបរទេស ពិសេសឯកសារជាភាសាខ្មែរ ឬ អក្សរខ្មែរ ដែលមានខ្លឹមសារផ្ទុយពីវត្ថុបំណងនៃរបបកុម្មុយនិស្តយួន ។

ទី៤-គឺការជួយផ្សព្វផ្សាយឲ្យបានស៊ីជម្រៅទៅក្នុងស្រទាប់មហាជននូវចំណងមិត្តភាព និងបំណាច់របស់ប្រជាជន បក្ស និងរដ្ឋអំណាចកុម្មុយនិស្តយួន ។ ខ្លឹមសារនៃសម័យប្រជុំនេះ បើតាមព្រះគ្រូពហុសូត្រមួយព្រះអង្គ ដែលព្រះអង្គអះអាងថា វត្តរបស់ព្រះអង្គមានព្រះសង្ឃភៀសខ្លួនទៅកម្ពុជាច្រើនជាងវត្តដទៃនោះ បានបង្ហើបឲ្យដឹងថា គេនឹងដាក់ទោសជាទម្ងន់ចំពោះជនណា ដែលមិនអនុវត្តតាមខ្លឹមសារនៃសម័យប្រជុំនេះ ។



បួសនាគ នៅកម្ពុជាក្រោម

ជុំវិញបញ្ហាស្តីពីមិត្តភាព ឬ គុណបំណាច់របស់បក្ស និងរដ្ឋអំណាចកុម្មុយនិស្តយួននោះ តាមញោមវត្ត វត្តចុងព្រលាន បានបំភ្លឺថា "កុំជឿឲ្យសោះ យួននិងខ្មែរ គ្មានមិត្តភាពឯណាទេ មើលចុះខ្មែរដែលរួមកម្លាំងនឹងយួនធ្វើសង្គ្រាមដើម្បីផលប្រយោជន៍រួមគ្នានោះ ពេលនេះ តើខ្មែរយើងបានអ្វីខ្លះ? អស់លោកនោះរាប់ពាន់នាក់ធ្លាក់ខ្លួនពិការ និងរាប់ពាន់នាក់ស្លាប់អសារបង់ ហើយប្រជាជនខ្មែររបស់ខ្លួននៅតែរងអំពើប្រល័យពូជសាសន៍ពីសំណាក់យួនដដែល ។ ឯរឿងគុណបំណាច់របស់យួនមកលើខ្មែរនោះ រឹតតែគ្មានទៅទៀត មើលចុះសព្វថ្ងៃដីស្រែចម្ការខ្មែរ ត្រូវគេប្រើល្បិចប្លន់យកអស់ ខ្មែរត្រូវធ្លាក់ខ្លួនក្រគ្រប់ភូមិស្រុក ចោលផ្ទះចោលសម្បែង ដើរស៊ីឈ្នួលគេស្ទើរគ្រប់ទីប្រជុំជន រហូតទៅដល់កម្ពុជាថែមទៀត ។

ចំណែកបញ្ហាយួនប្រកាសថា នឹងដាក់ទោសជាទម្ងន់ចំពោះបុគ្គលណា ដែលមិនអនុវត្តតាមខ្លឹមសារនៃសម័យប្រជុំ ឬ ផែនការណ៍របស់យួននោះ ព្រះភិក្ខុមួយអង្គ គង់នៅវត្តបាត់ក្រមា ស្រុកកំពង់ស្ពាន បានបង្ហាញថា រឿងនោះយួននឹងអនុវត្តមែន តួយ៉ាងគឺដូចកាលថ្ងៃទី ២៤ មិនា ឆ្នាំ ២០០៥ គេបានចាប់ផ្សឹកភិក្ខុ ថាច់ លីភោ គង់នៅវត្តកំពង់ស្ពាន ស្រុកជុំក្រុង ខេត្តព្រះត្រពាំង ដោយគ្មានជំនុំជម្រះក្តីថែមទៀត ដោយសារតែព្រះភិក្ខុ ថាច់ លីភោ ផ្សព្វផ្សាយឯកសារដែលនិយាយការពិតពីសោកនាដកម្មខ្មែរកម្ពុជាក្រោម ។ តែដើម្បីធ្វើទោសដល់ភិក្ខុ ថាច់ លីភោ គេបែរជាបង្កល្បិចផ្សេង ដើម្បីចោទប្រកាន់ព្រះអង្គទៅវិញ ព្រោះយួនគេខ្លាចមតិជាតិ និងអន្តរជាតិថ្កោលទោសគេថា ដាក់ទោសដល់ខ្មែរក្រោម ដែលគ្រាន់តែខ្មែរនិយាយរឿងពិតរបស់ខ្មែរនោះឯង ។

ព្រះអង្គបានបញ្ជាក់បន្ថែមទៀតថា "ឯរឿងដែលខ្មែរភៀសខ្លួននោះ ព្រះអង្គគ្មានសមត្ថភាព ហាមឃាត់បានទេ រឿងនេះវាអាស្រ័យលើរដ្ឋាភិបាល បើប្រសិនជារដ្ឋាភិបាលគោរពសិទ្ធិមនុស្សជាមូលដ្ឋាន រួមទាំងសិទ្ធិជាជនជាតិដើម ឲ្យបានត្រឹមត្រូវនោះ ប្រាកដជាគ្មានការភៀសខ្លួន ហើយជនភៀសខ្លួនដែលបានរត់ទៅកម្ពុជាថ្មី ៗ នេះ ក៏ត្រូវប្រហែលជានឹងវិលមកវិញដែរ ៕

VOKK

# អគ្គីភ័យ បំផ្លាញផ្ទះសម្បែងបងប្អូនខ្មែរក្រោម



ទិដ្ឋភាពផ្ទះសម្បែងត្រូវភ្លើងឆេះបំផ្លាញអស់

គ្រោះអគ្គីភ័យមួយបានកើតឡើង នៅភូមិសាមគ្គី សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីម៉ោង ៣ រសៀល នាថ្ងៃទី ៩ តុលា ឆ្នាំ ២០០៥ កន្លងទៅនេះ ។

គ្រោះអគ្គីភ័យនេះ បានដុតបំផ្លាញធ្វើឲ្យផ្ទះសម្បែងរបស់ប្រជាជនជាង ៥៥ ខ្នងត្រូវឆេះគ្មានសល់ ។ ក្នុងនោះក៏មានផ្ទះរបស់បងប្អូនខ្មែរក្រោមមួយចំនួនធំផងដែរ ដែលត្រូវរងគ្រោះ ។ ប៉ុន្តែគ្រោះអគ្គីភ័យនេះ ពុំបានយាយីដល់អាយុជីវិតរបស់បងប្អូនដែលស្ថិតនៅក្នុងភូមិសាមគ្គីឡើយ ។

លំនៅឋានដែលត្រូវភ្លើងឆេះនេះ ស្ទើរតែទាំងអស់ធ្វើឡើងអំពីឈើ ប្រក់សង្កសី ដែលសង់ជាប់ ៗ គ្នាទើបបណ្តាលឲ្យភ្លើងឆេះយ៉ាងសន្ធោសន្ធៅ ក្នុងរយៈពេលប្រមាណជាងមួយម៉ោងប៉ុណ្ណោះ ។ រីឯរថយន្តពន្លត់អគ្គីភ័យ ក៏មានការលំបាកក្នុងការជួយសង្គ្រោះ នោះដោយសារតែផ្លូវចូលតូចពេក ។

មូលហេតុដែលនាំឲ្យកើតមានគ្រោះអគ្គីភ័យនេះ បើតាមសំដីរបស់មន្ត្រីប៉ូលិសមូលដ្ឋានបានឲ្យដឹងថា គឺបណ្តាលមកពីក្មេង ៗ ឈ្លោះគ្នា ហើយបានគប់ចង្កៀងប្រេងកាតទៅលើចង្ក្រាន ទើបបណ្តាលឲ្យភ្លើងឆេះរាលដាលពីផ្ទះមួយទៅផ្ទះមួយយ៉ាងឆាប់រហ័សបែបនេះ ។

ក្នុងចំណោមផ្ទះដែលត្រូវភ្លើងឆេះទាំងនោះ មានគ្រួសារខ្មែរក្រោមប្រមាណជាង ៥០ គ្រួសារ ។ ហើយក្នុងនោះមានផ្ទះរបស់គ្រួសារខ្លះជាកម្មសិទ្ធិផ្ទាល់ និង គ្រួសារខ្លះទៀតជាផ្ទះជួល ។ បងប្អូនខ្មែរក្រោមដែលមានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ហើយត្រូវរងគ្រោះដោយអគ្គីភ័យនេះ មានប្រមាណ ១៥ ខ្នង រីឯប៉ុន្មានខ្នងដទៃទៀត គឺជាផ្ទះជួលគេ ។

លោកអ៊ំ ស្រ៊ុ មានដើមកំណើតនៅកម្ពុជាក្រោម ខេត្តឃ្លាំង ដែលមានផ្ទះជាកម្មសិទ្ធិផ្ទាល់ត្រូវរងគ្រោះនោះ បានឲ្យដឹងថា ផ្ទះរបស់គាត់ត្រូវភ្លើងឆេះអស់ហើយ រួមទាំងទ្រព្យសម្បត្តិបន្តិចបន្តួចដែលគាត់ខំរកបាន ហើយគាត់មានការសោកស្តាយយ៉ាងខ្លាំង ដោយសារគ្រួសារគាត់កំពុងតែខ្វះខាតផង ។

រីឯលោក រិន ដែលមានកំណើតនៅកម្ពុជាក្រោមដែរនោះ គាត់និយាយថា គាត់មានការសោកស្តាយយ៉ាងខ្លាំងនូវទ្រព្យសម្បត្តិដែលគាត់ និងក្រុមគ្រួសារខិតខំសន្សំរកបាន ។

ចំណែកលោក យ៉េត ក៏ជាជាតិខ្មែរក្រោមដែរ ដែលមានផ្ទះជញ្ជាំងឈើប្រក់សង្កសី ហើយបានត្រូវរងគ្រោះដោយអគ្គីភ័យនោះ លោកក៏មានការសោកស្តាយយ៉ាងខ្លាំងណាស់ដែរនូវទ្រព្យសម្បត្តិដែលគ្រួសារលោកមាន និងមិនគួរត្រូវបានបំផ្លាញដោយភ្លើងដូច្នេះសោះ ។

ក្រោយពេលដែលអគ្គីភ័យនេះកើតឡើង គេសង្កេតឃើញមានបងប្អូនខ្មែរក្រោមមួយចំនួន ដែលមានទីលំនៅផ្សេង ៗ ពីកន្លែងកើតហេតុ បានឮដំណឹងភ្លាមនោះ អ្នកខ្លះបាននាំយកសំលៀកបំពាក់មួយចំនួន រួមទាំងអង្ករផងដែរ មកជូនបងប្អូនដែលត្រូវរងគ្រោះដោយអគ្គីភ័យនេះ ៕

ដោយ វិស័យ



បងប្អូនប្រជាជន យំស្តាយស្រណោះ
ព្រោះផ្ទះសម្បែងត្រូវភ្លើងឆេះបំផ្លាញគ្មានសល់

# ទូកងនិស្សិតខ្មែរក្រោមលេខ ១ ទៀតហើយ

ក្រុមទូកងនិស្សិតខ្មែរកម្ពុជាក្រោម នៅរដ្ឋវ៉ាស៊ីនតោន នៃសហរដ្ឋអាមេរិក បានចូលរួមប្រណាំងទូក កាលពីថ្ងៃទី ១៧ ខែកញ្ញា កន្លងទៅនេះ នៅទីក្រុង តាខូម៉ា (Tacoma) រដ្ឋវ៉ាស៊ីន-តោន នៃសហរដ្ឋអាមេរិក ។ ពិធីប្រណាំងទូកងនេះ ត្រូវបានប្រារព្ធធ្វើឡើង ដោយមានការចូលរួមប្រកួតពីសំណាក់ក្រុមកីឡាករទូកង ១៣ ក្រុម ដែលធ្វើដំណើរមកពីទីក្រុងទាំង ៦ ដូចជា ៖ ក្រុង ខេនត៍ (KENT), ក្រុង ស៊ីអាធីល (SEATILE) ក្រុង ផតឡែន (PORTLAND), ក្រុង អូឡាំផ្យ៉ា (OLYMPIA) ក្រុង ហ្វៃ (FIFE) និង ក្រុង តាខូម៉ា (TACOMA) ។

ការប្រណាំងចែកជា ២ វគ្គ គឺ ៖

វគ្គទី ១ ប្រណាំងក្នុងចម្ងាយ ២៥0 ម៉ែត្រ ៖

ជាលទ្ធផល ៖ លេខ 0១ បានទៅលើ ក្រុមស៊ីមសុន (Simpson) ទទួលបានមេដៃមាស ។ លេខ 0២ បានទៅលើ ក្រុមនិស្សិតខ្មែរក្រោម ទទួលបានមេដៃប្រាក់ ។ លេខ 0៣ បានទៅលើ ក្រុមខូឡំប្យ៉ា ប៊ែង (Columbia bank) ទទួលបានមេដៃស្ពាន់ ។

វគ្គទី ២ ប្រណាំងក្នុងចម្ងាយ ៥00 ម៉ែត្រ ៖

ជាលទ្ធផល ៖ លេខ 0១ បានទៅលើ ក្រុមខ្មែរក្រោម ទទួលបានមេដៃមាស ។ លេខ 0២ បានទៅលើ ក្រុម វីនតេកសេក (Vintage Sake) ទទួលបានមេដៃប្រាក់ ។ លេខ 0៣ បានទៅលើ ក្រុមខេនត៍ ដ្រាហ្គន់ បូត (Kent Dragon boat) ទទួលបានមេដៃស្ពាន់ ។

សរុបលទ្ធផលមកឃើញថា ក្រុមទូកងខ្មែរក្រោម ទទួលបានចំណាត់ថ្នាក់ល្អគួរឲ្យស្ញើចសរសើរ ។ នេះក៏ដោយសារតែការខំប្រឹងប្រែងប្រកួតប្រជែងយ៉ាងអស់ពីសមត្ថភាព រួមផ្សំនឹងសាមគ្គីភាព ភាពស៊ីសង្វាក់គ្នា រវាងកីឡាករខ្មែរក្រោមគ្រប់រូប រហូតដណ្តើមបានជោគជ័យនៅក្នុងការប្រណាំងនេះ ។

ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ខ្មែរមានសក្តានុ-ពលភាពខ្លាំងខាងធ្វើចំបាំងផ្លូវទឹក ដូចមានចំលាក់នៅជញ្ជាំងប្រាសាទបាយ័នជាភស្តុតាងស្រាប់ ។ រហូតមកដល់សព្វថ្ងៃនេះ ខ្មែរនៅតែរក្សាបាននូវស្នាដៃដ៏អស្ចារ្យខាងប្រណាំងទូក ។ ក៏ដូចជាខ្មែរកម្ពុជាក្រោមដែលដណ្តើមបានជោគជ័យនៅលើឆាកអន្តរជាតិ ស្នងមរតកស្នាដៃនៃបុព្វបុរសខ្មែរ ។

កត្តានេះ បានធ្វើឲ្យខ្មែរក្រោមកាន់តែមានភាពលេចធ្លោនៅលើឆាកអន្តរជាតិ ។ ហើយសង្ឃឹមថា ខ្មែរក្រោម នឹងទទួលបានចំណាក់ថ្នាក់ល្អ ៗ ក្នុងការប្រណាំងទូកដទៃទៀត ។

ចៅតីនិស្សចៅ



រូបថតអនុស្សាវរីយ៍ក្រុមកីឡាករទូកង និស្សិតខ្មែរកម្ពុជាក្រោម



សុន្ទរកថារបស់កីឡាករទូកង និស្សិតខ្មែរកម្ពុជាក្រោម

# សម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម បើកមហាសន្និបាតសាមញ្ញ

**សម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម (ស.ខ.ក.ក) ដែលមានទីតាំងនៅវត្តអង្គពោធិញាណ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ បានប្រារព្ធអង្គមហាសន្និបាតសាមញ្ញអាណត្តិទី ១ លើកទី ១ (អាណត្តិ ៤ឆ្នាំ) របស់ខ្លួន កាលពីថ្ងៃទី ១៥-១៦ ខែតុលា ឆ្នាំ ២០០៥ នៅវត្តព្រែកប្រា សង្កាត់ព្រែកប្រា រាជធានីភ្នំពេញ ក្រោមអធិបតីភាពព្រះអង្គម្ចាស់ក្សត្រីស៊ីសុវត្ថិ នារីមុនីពង្ស និងមានសមាជិកសមាជិកា ព្រមទាំងភ្ញៀវកិត្តិយសប្រមាណ ២០០ នាក់ ។ អង្គមហាសន្និបាតប្រារព្ធឡើង ក្នុងគោលបំណងជ្រើសរើសថ្នាក់ដឹកនាំថ្មីនៃ ស.ខ.ក.ក ព្រមទាំងសិក្សាទិសដៅទ្រទ្រង់ វប្បធម៌ និង ស្ថេរភាពខ្មែរនៅកម្ពុជាក្រោមបច្ចុប្បន្ន ។**



ព្រះអង្គម្ចាស់ក្សត្រីស៊ីសុវត្ថិ នារីមុនីពង្ស ទ្រង់ថ្លែងសុន្ទរកថាក្នុងអង្គសន្និបាត

មហាសន្និបាតបានប្រារព្ធឡើង ដោយសុន្ទរកថាស្វាគមន៍ ថ្លែងដោយលោក សឺន សែត ទីប្រឹក្សា ស.ខ.ក.ក ។ លោកបានរំឭកឡើង នូវទំព័រអនុស្សាវរីយ៍នៃប្រវត្តិសាស្ត្រដ៏ជូរចត់របស់ខ្មែរកម្ពុជាក្រោម ដែលត្រូវបាត់បង់សិទ្ធិលើកំណើតរបស់ខ្លួន ហើយពេលវេលាបន្តទៅ គឺត្រូវប្រឈមមុខនឹងការបាត់បង់ពូជសាសន៍ខ្មែរនៅកម្ពុជាក្រោម ។ មូលហេតុនោះគឺភាពក្រីក្រ ជីវភាពក្រីក្រដ៏សែនតោកយ៉ាកនេះ បានក្លាយជាព្យុះកំណាច គ្របសង្កត់មកលើខ្មែរកម្ពុជាក្រោម ចាប់តាំងពីឆ្នាំ ១៩៨៤ រហូតមក គឺចាប់តាំងពីរបបអាណានិគមយួនរបស់លោក ឡេ យន់ (ប្រធានាធិបតីប្រទេសវៀតណាម) ចាប់រឹបអូស ដកហូតដីស្រែពីប្រជាកសិករខ្មែរនៅស្ទើរគ្រប់ទីកន្លែង ។ ទន្ទឹមនឹងរឹបអូសយកដីស្រែ រដ្ឋាភិបាលយួន បានអនុវត្តផែនការ តាមចាប់ខ្លួនខ្មែរ អ្នកធ្លាប់បួសរៀនអក្សរច្បាប់ក្បួនទំនៀមទំលាប់ប្រពៃណីជាតិ នៅក្នុងវត្តអារាមព្រះពុទ្ធសាសនាខ្មែរ ។ ព្រះសង្ឃបួសក្នុងវត្តក៏គេចាប់ផ្សឹក ទាំងឧបាសក ប្រុសស្រីយកដាក់ពន្ធនាគារ ធ្វើទារុណកម្ម សូម្បីតែបុគ្គលិក មន្ត្រីរដ្ឋការរដ្ឋាភិបាល បេក្ខជនបក្សកុម្មុយនិស្តយួន ដែលមានដើមកំណើតខ្មែរក៏ត្រូវគេចាប់យកទៅដាក់ពន្ធនាគារ និងធ្វើទារុណកម្មរហូតដល់ទទួលមរណៈនៅក្នុងពន្ធនាគារ ។ ហើយក្នុងចំណោមអ្នកស្លាប់ដោយទារុណកម្មនោះ មានវីរសាមណៈពីរព្រះអង្គ គឺព្រះអង្គមហាវីរៈសាមណៈ គឹម តុកចើង និង ព្រះមហាវីរៈសាមណៈ គឹម សាង ។ល។

បន្ទាប់ពីសុន្ទរកថាបើកអង្គសន្និបាត បានកន្លងផុតទៅ ព្រះអង្គម្ចាស់ក្សត្រីស៊ីសុវត្ថិ នារីមុនីពង្ស ដែលជាអធិបតីនៃមហាសន្និបាតសាមញ្ញនេះ ទ្រង់ថ្លែងសេចក្តីកោតសរសើរក្នុងអង្គមហាសន្និបាតថា៖ “ខ្ញុំព្រះករុណាខ្ញុំសូមកោតសរសើរ និងថ្លែងអំណរព្រះគុណនិងអរគុណដ៏ជ្រាលជ្រៅចំពោះសម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម ដែលបានរៀបចំមហាសន្និបាតនាឱកាសនេះ ស្វែងរកបទពិសោធន៍ល្អ ៗ សំរាប់ជាគុណប្រយោជន៍របស់សម្ព័ន្ធ ។ ការជួបជុំនៅពេលនេះ បានបង្ហាញឲ្យឃើញនូវទឹកព្រះទ័យព្រះថេរានុត្ថេរៈ សមណនិស្សិតគ្រប់ព្រះអង្គ និងទឹកចិត្តបងប្អូនជនរួមជាតិសហការគ្នា លើកកំពស់ការទទួលខុសត្រូវ ក្នុងការដឹកនាំសហគមន៍” ។

ក្នុងការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំ អាណត្តិថ្មីនេះមានបេក្ខជន ៨ អង្គ-រូប ដែលស្វែងរកសំឡេងគាំទ្រ គឺ ភិក្ខុ ថៅ សាង, ភិក្ខុ សេរី អមតៈ, ភិក្ខុ ស៊ីម ប៉ន, ភិក្ខុ សារ ម៉ោរ៉ា, ភិក្ខុ សួន កុសល, ភិក្ខុ សួគ៌ វិបុល, ភិក្ខុ សៅ សុធា និង កញ្ញា ហង្ស ធីតា ។

លទ្ធផលនៃការបោះឆ្នោតគឺ សមណនិស្សិត ថៅសាង ព្រះជន្ម ៣៦ វស្សា គង់នៅវត្តបទុមវតី ជាប់ជាប្រធានថ្មីនៃ ស.ន.ក.ក ។ សមណនិស្សិត សួគ៌ វិបុល ព្រះជន្ម ៣០ វស្សា ជាប់ជាអនុប្រធាន ទី ១ និង និស្សិត ហង្ស ធីតា (ភេទស្រី ) អាយុ ៣៨ ឆ្នាំជាប់ជាអនុប្រធានទី ២ ។

អស់រយៈពេលពីរថ្ងៃ នៃការពិភាក្សាសិក្សារែកញែកយ៉ាងផុសផុល ហើយដើម្បីរក្សាឲ្យបាននូវស្ថិរភាព និងភាពវិវឌ្ឍទៅមុខចំពោះស្ថានភាពខ្មែរនៅកម្ពុជាក្រោមលើគ្រប់វិស័យ អង្គមហាសន្និបាត បានអនុម័តបន្តឲ្យកាន់តែរីកចំរើនថែមទៀត នូវគោលការណ៍កសាងសម្បត្តិមនុស្ស (ធនធានមនុស្ស) ផ្អែក

លើកគ្គា ៖

ទី ១- ជំរុញឲ្យកុលបុត្រខ្មែរក្រោមរៀនឲ្យបានដល់មហាវិទ្យាល័យគ្រប់ ៗ គ្នា ។

ទី ២- ខិតខំបញ្ជូននិស្សិតចេញទៅបំពេញកម្មសិក្សានៅក្រៅប្រទេសឲ្យបានច្រើន ព្រោះនៅក្នុងប្រទេស (កម្ពុជាក្រោម) គ្មានភាពជឿនលឿនចំពោះចំណេះភាសាខ្មែរនោះទេ ។

ទី ៣- បង្កើតគ្រឹះស្ថានសិក្សាអប់រំយ៉ាងហោចណាស់ក៏ឲ្យបានត្រឹមកំរិតបឋម និងមុខជំនាញផ្សេង ៗ ដូចជាប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រនៅតាមបណ្តាទីក្រុងប្រជុំជន ដែលមានខ្មែរក្រោមរស់នៅ និងកសាងកុដិសាលាតាមវត្តអារាមសំរាប់សមណនិស្សិត និស្សិតស្នាក់នៅរៀនសូត្រ ។

ទី ៤- បង្កឲ្យមានការងារធ្វើដល់សិស្សនិស្សិតដែលបញ្ចប់ការសិក្សា ។

នៅចុងបញ្ចប់នៃអង្គមហាសន្និបាត បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតរួច ។ ថ្នាក់ដឹកនាំថ្មីនៃសម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោមបានឡើងប្តេជ្ញាចិត្តថា នឹងខិតខំពុះពារគ្រប់ឧបស័គ្គ ព្រមទាំងរួមសហការជាមួយបណ្តាអង្គការដែលជាមិត្ត ជំរុញឲ្យបាននូវគោលការណ៍ដែលអង្គមហាសន្និបាតបានដាក់ចេញ ដើម្បីកសាងឲ្យរឹងមាំនូវភាពគង់វង្សពូជសាសន៍ខ្មែរកម្ពុជាក្រោម ៕ *ចៅឥទ្ធិចៅ*

# ខ្មែរក្រោមនៅជីកាហ្គោ ស្វាគមន៍សហព័ន្ធខ្មែរកម្ពុជាក្រោម

គណៈប្រតិភូសហព័ន្ធខ្មែរកម្ពុជាក្រោម បានចុះទៅបំពេញបេសកកម្មការងារនៅទីក្រុងជីកាហ្គោ (CHICAGO) សហរដ្ឋអាមេរិក កាលពីថ្ងៃទី ១៥ ខែតុលា កន្លងទៅនេះ ។ ក្នុងបេសកកម្មនេះដែរ សហព័ន្ធខ្មែរកម្ពុជាក្រោមត្រូវបានការទទួលអបអរសាទរយ៉ាងកក់ក្តៅ អំពីសំណាក់បងប្អូនខ្មែរក្រោមជាង ៤០ គ្រួសារ ។



គណៈប្រតិភូ នៃសហព័ន្ធខ្មែរកម្ពុជាក្រោម

អស់រយៈពេលពេញមួយថ្ងៃក្នុងការជួបជុំ សហព័ន្ធបានពន្យល់ណែនាំដល់បងប្អូន ដែលកំពុងរស់ក្នុងរដ្ឋជីកាហ្គោនេះ អំពីបេសកកម្ម និង គោលបំណងរបស់សហព័ន្ធខ្មែរកម្ពុជាក្រោមទៅអនាគត ។ សហព័ន្ធខ្មែរកម្ពុជាក្រោម គឺជាអង្គការមួយដែលមិនសំដៅលើប្រាក់ចំណេញ គឺប្រយុទ្ធដោយអហិង្សាស្របទៅតាមច្បាប់នៃអន្តរជាតិ ដើម្បីគាំទ្រឲ្យមានសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ សំរាប់បងប្អូនខ្មែរក្រោមដែលកំពុងរស់នៅលើដែនដីកំណើតរបស់ខ្លួន ។ បងប្អូននៅជីកាហ្គោ មានសេចក្តីកក់ក្តៅយ៉ាងខ្លាំង នៅពេលដែលបានដឹងនូវរចនាសម្ព័ន្ធ និងគោលបំណងរបស់សហព័ន្ធ ។ នៅក្នុងសុន្ទរកថានេះដែរ គណៈប្រតិភូបានរំឭកអំពីទង្វើជិះជាន់ បំបាត់ជំនឿសាសនា សេរីភាពបញ្ចេញមតិ តែបន្លំនូវទំនៀមទំលាប់ និង វិស័យរៀនសូត្រពីសំណាក់អាណានិគមយួន ។ មិនតែប៉ុណ្ណោះ ធ្វើឲ្យខ្មែរក្រោមត្រូវពិការភ្នែកជាង ៣០០០ នាក់ តែពុំមានរដ្ឋាភិបាលណាមួយអើពើ ឬស្រាវជ្រាវឲ្យដឹងពីមូលហេតុឡើយ ។ល។ សុន្ទរកថានេះ ត្រូវបានបងប្អូននៅរដ្ឋជីកាហ្គោគាំទ្រ និងអបអរយ៉ាងខ្លាំង ។ បន្ទាប់ពីនោះ សហព័ន្ធក៏បានជ្រើសរើសសមាជិកពីររូប រួមមានលោក ថាច់ ស៊ឺន ជាប្រធានសមាគមយុវជន និងអ្នកស្រី ឡេ សាភៀរ ជាប្រធាននៃសមាគមស្ត្រី ។

ចុងបញ្ចប់នៃការជួបជុំនេះ សហព័ន្ធខ្មែរកម្ពុជាក្រោមចាត់ទុកថានេះ គឺជាជោគជ័យមួយដ៏ប្រវត្តិសាស្ត្រ ចំពោះសហព័ន្ធខ្មែរកម្ពុជាក្រោម និងបងប្អូនខ្មែរក្រោមដែលនៅរដ្ឋជីកាហ្គោ ។ ជាចុងបញ្ចប់នៃសុន្ទរកថានេះដែរ លោក តោ គឹមថុង ដែលជាអធិបតីនៃសហព័ន្ធ បានថ្លែងថា ៖ "យើងគឺជាគ្រួសារតែមួយ ត្រូវចេះស្រលាញ់ និងរួបរួមសាមគ្គីគ្នា" ៕

**ចៅជ័យ**

# រឿងកំពប់តែអុង

> អត្ថបទកំណាព្យនេះ ត្រូវបានរក្សាទុកអក្ខរាវិរុទ្ធ
> តាមច្បាប់ដើមទាំងស្រុង

## សាស្ត្រាវត្តក្រូច – រៀបរៀងដោយសាស្ត្រាចារ្យ ឃឹន សុខ



យួនយកក្បាលខ្មែរធ្វើជាមុំចង្ក្រានកល់ដាំតែអុង

៥៦៩-ជាមួយបំរើ        កូនក្មួយលោកដើរ
    ដង្ហែពាសពេញ        កាន់អស់គ្រឿងគ្រប់
    ប្រដាប់ចរចេញ        បំរើនោះមិញ
    ជំរាបលោកថា ។

៥៧០-ម្ដេចលោកគិតឲ្យ នុស្សទៅតាមក្រោយ
    កាន់គ្រឿងសាស្ត្រា        គ្រប់ដៃរដូច្នេះ
    ច្រើនម្លេះត្រៀបត្រា        ក្រែងអុងលោកថា
    ចាប់ទោសចាប់ពៃរ្យ ។

៥៧១-និយាយតាមផ្លូវ        តរាបរៀងទៅ
    ប្រជែងទីទៃ        លោកព្រះអង្គម៉ា
    ថាអុងនោះនៃ        កាន់គ្រឿងគ្រប់ដៃ
    យល់ជាមានការ ។

៥៧២-ទើបអង្គអញឯង ឲ្យគិតតាក់តែង
    កាន់គ្រឿងគ្រប់គ្នា        បើអុងមានក្រ
    កម្រម្ដេចម្ដា        យកគ្រឿងពីណា
    និងឲ្យជួយអុង ។

៥៧៣-និយាយតាមផ្លូវ        ដរាបរៀងទៅ
    ទៀបដល់រំលុង        ថុងងួនបាសារ
    ថាលោកនៅក្នុង        ផ្ទាញទៅហៅអុង
    ត្រង់ក្ដានោះឯង ។

៥៧៤-ឯលោកព្រះអង្គ        ដឹងហើយបង្អង់
    ដឹងដើមយល់ឆ្វេង        គេជីករំលង់
    បំផុងអង្គឯង        លោកហៅមនុស្សតែង
    ទុកចិត្តចូលទៅ ។

៥៧៥-ហើយបង្គាប់ថា        ឲ្យអស់ព្រះពញា
    កូនក្មួយចូលទៅ        ចាំទិមទ្វារផ្ទាញ
    អង្គអញចូលទៅ        ទាំងអស់ឲ្យនៅ
    នៅតែពីរនាក់ ។

៥៧៦-ផ្ដាំស្រេចដូច្នេះ        លោកលោតផ្លោតផ្លោះ
    ហួសក្ដារយួនដាក់        កូនក្មួយលោកតាម
    ទៅទាំងពីរនាក់        យួនយល់ឃើញជាក់
    ចូលទៅដូច្នេះ ។

៥៧៧-ឯយួនចាំទ្វារ        អររឯងម្ទីម្ទារ
    រួសរាំងទ្វារនោះ        ថាអុងទន្ទឹង
    លោកបាត់សូនសោះ អញ្ជើញទៅចុះ
    អុងរុងចាំនៅ ។

៥៧៨-ឯលោកព្រះអង្គ        ចចូលដល់ក្នុង
    រោងជិតទៀបទៅ        អស់ទាំងទាសា
    ភ្នាក់ងាយួននៅ        ថាឲ្យលោកទៅ
    លើកៅអីនោះ ។

៥៧៩-ឯលោកព្រះអង្គ        ពុំទាន់ហៅអុង
    ឲ្យអស់ពីពោះ        ដូចដោយសេណី
    មន្ត្រីទាំងនោះ        ឲ្យអស់ពីពោះ
    ច្រហោងស្មៀមនៅ ។

៥៨០-អុងឲ្យទាសារ        ថុងងួននោះថា

ឲ្យលោកឡើងទៅ អង្គុយកៅអី
ឲ្យធ្លាក់រណ្ដៅ លោកដឹងមិនទៅ
ថាអណាស់ហើយ ។
៥៨១-ឯអុងបាហោ តែងទៀនប្រាប់មក
ញ៉ឹកៗជាត្រើយ រីឯព្រះអង្គ
ថាអុងអរហើយ ពិតពុំឡើងឡើយ
អង្គុយស្ងៀមនៅ ។
៥៨២-អុងដឹងដូច្នេះ ប្រើទាសារនោះ
មកប្រែប្រាប់ថា ថាម្ដេចព្រះអង្គ
ដល់អុងមិនហៅ ហើយកាន់គ្រឿងគ្រៅ
គ្រប់ដៃមកផង ។
៥៨៣-ឯច្បាប់យើងយួន ឲ្យដង្ហែរខ្លួន
ចូលមកនេះឆ្លង ហើយកាន់គ្រឿងគ្រប់
ប្រដាប់មកផង ប្រកួតប្រឡង
យកស័ក្ដិអ្នកធំ ។
៥៨៤-ឯព្រះអង្គម៉ា បានឆ្លើយវិញថា
ខ្ញុំគិតអារម្ម ប្រយ័ត្នរាជការ
ជួយអុងជាធំ ទើបឲ្យមនុស្សខ្ញុំ
កាន់គ្រឿងប្រដាប់ ។
៥៨៥-ក្រែងអុងមានក្រ ហើយបង្គាប់មក
មានគ្រឿងគ្រប់ស្រាប់ ខ្ញុំគិតដូច្នេះ
ហេតុនេះបង្គាប់ ឲ្យកាន់ប្រដាប់
គ្រឿងគ្រប់មកផង ។
៥៨៦-កាលនោះឯអុង ស្ដាប់ពាក្យព្រះអង្គ
ឆ្លាសឆ្លើយសារសង អុងអរសើចមក
ចំអកឲ្យផង ក្អាកក្អាយសូរសង
ទើបថុងងួនថា ។
៥៨៧-អុងស្រដីលេង និងព្រះអង្គឯង
កុំអន់ចិន្ដា ព្រះអង្គឮហើយ
ឆ្លាសឆ្លើយវិញថា ខ្ញុំអរហើយណា
និងអុងស្រាកស្រួល ។
៥៨៨-កាលនោះឯអុង ឲ្យគិតអម្រុង
បាយទឹកទទួល ទើបព្រះអង្គម៉ា
ថាពោះមិនស្រួល មិនដែលទទួល
ទានច្រើនវេលា ។

៥៨៩-បានតែម្ដងៗ បើខ្ញុំរំលង
កំណដ្ឋមិនថា កុំព្រួយអុងឲ្យ
រកវៀបក្រយ៉ា ខ្ញុំអរណាស់ណា
និងចិតអុងស្មោះ ។
៥៩០-អស់លោកទាសា ពិតអុងផងណា
ថាខ្ញុំហើមពោះ កុំឲ្យរៀបថ្វី
ចំណីអស់នោះ ឲ្យតែពីគ្រោះ
រាជការនឹងទៅ ។
៥៩១-បទខ្ញុំមកឈុប ពីពុនព្រលប់
លុះអាធ្រាតជ្រៅ អុងមិនឃើញថា
រាជការស្ងៀមនៅ ខ្ញុំចង់លាទៅ
ឥឡូវនេះហើយ ។
៥៩២-ឯអុងបាហោ ដឹងហើយខឹងម
កុំអាលទៅឡើយ ឯលោកព្រះអង្គ
រុងនៅគិតហើយ អុងស្ងៀមព្រងើយ
លោកលាចេញទៅ ។
៥៩៣-ថុងងួនបាសា តាមឃាត់រាំងរា
ពីមុនមិននៅ ឯអស់ទាសា
ថាកុំអាលទៅ លោកពុំព្រមនៅ
ចេញទៅក្រៅថ្នាញ ។
៥៩៤-ជួបនិងអស់មនុស្ស ព្រមគ្នាទាំងអស់
ទៅផ្ទះវិងវិញ ប្រាប់អស់បរិពារ
គ្នីគ្នានោះមិញ រៀបរូតស្រេចចេញ
ទៅបាត់ដំបង ។
៥៩៥-បទព្រហ្មគិតគាប់ ចចារចាប់ៗចែងចង
កាលក្រោយបន្តិចហោង រាជតេជៈកសគិតការ ។
៥៩៦-គាត់គិតក្នុងចិន្ដា ចង់បានជាងជាឃោមរាជ
ហេតុការគិតមិនខ្លាច នៃឃោមរាជហ៊ូវនោះឡើយ ។
៥៩៧-ប្រទូសប្រទាស់គ្នា តែពីងារនោះជាត្រើយ
ខីខឹងពុំស្បើយឡើយ ហើយទៅទូលមហាក្សត្រ ។
៥៩៨-ឯអង្គមហាក្សត្រា ព្រួយព្រះទ័យក្របើថា
ឃោមរាជឥតទោសា និងហូតងារគេពុំខុស ។
៥៩៩-ទើបក្សត្រក្សាន្តឥសូរ មានបន្ទូលថាអាកស់
ឃោមរាជគេមិនខុស និងជម្លោះងារម្ដេចបាន ។

**(នៅមានត)**

## សំណាកព្រះបាទជ័យវរ្ម័នទី ៧

# មាន ២ ទ្រង់តាំងសមាធិ និង ទ្រង់អញ្ជលី

រូបសំណាកព្រះបាទជ័យវរ្ម័នទី ៧ ដែលគេបានសាង សង់ជាសភាពពិការព្រះហស្តទាំងសងខាង និងបែកព្រះកេស ជាយូរមកហើយ ដើម្បីយកទៅតាំងនៅសួនច្បារ និងគេហដ្ឋាន នោះ ឥឡូវនេះត្រូវបានស្រាវជ្រាវរកឃើញគ្រប់លក្ខណៈទ្រង់ ទ្រាយពិតប្រាកដហើយ ដែលមានពីរសណ្ឋានក្នុងនោះ មួយ ព្រះអង្គជារូបព្រះអង្គតាំងសមាធិ និងមួយទៀតជារូបព្រះអង្គ អញ្ជលី (សំពះ) ។

ការបង្ហាញឲ្យឃើញពីរូបសំណាក ដែលមានលក្ខណៈ ពេញទ្រង់ទ្រាយដើមនេះ ធ្វើឡើងនៅក្នុងសន្និសីទកាសែតមួយ ដែលរៀបចំដោយសមាគមជាតិ នៃសហគ្រាសទេសចរណ៍ កាលពីរសៀលថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០០៥ នៅហាងមី (Noodle Shop) ដោយមានការចូលរួមពីលោកមីសែល ត្រាណេ តំណាងក្រសួងដែលពាក់ព័ន្ធ និងអ្នកសារព័ត៌មាន យ៉ាងច្រើនកុះករ ។

លោក មឿង សុន អនុប្រធានសមាគមជាតិនៃសហគ្រាសទេសចរណ៍បានឲ្យដឹងថា ៖ ការបង្ហាញរូបសំណាកព្រះ បាទជ័យវរ្ម័នទី ៧ ពិត តាមទ្រង់ទ្រាយលក្ខណៈដើមនេះ ក្នុង គោលបំណងបញ្ជាក់ថា ៖ រូបសំណាកពិតមានសណ្ឋានបែប ណា ដើម្បីឆ្លើយតបទៅនឹងចំងល់របស់ប្រជាពលរដ្ឋកម្ពុជាទាំង មូល ក៏ដូចជាភ្ញៀវអន្តរជាតិដែលតែងតែងឿងឆ្ងល់ថា ៖ ហេតុអ្វី បានជានាំគ្នាសង់រូបសំណាករបស់ព្រះអង្គ ដែលពិការព្រះហស្ត ទាំងសងខាង និងបែកព្រះកេស ។ ហើយទន្ទឹមនឹងនោះសំណូមពររបស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងពាក់ព័ន្ធមួយចំនួន សង់រូបសំណាកឲ្យគ្រប់លក្ខណៈទ្រង់ទ្រាយដើមប្ដូររូបសំណាក ចាស់នោះជាការប្រសើរ ធ្វើឲ្យប្រទេសរុងរឿង និងអភិវឌ្ឍន៍ ។

លោក មឿង សុន បានបន្តថា ៖ ព្រះកិត្តិនាម ព្រម ទាំងគុណសម្បត្តិដ៏ធំធេងរបស់ ព្រះមហាវរក្សត្រពុទ្ធសាសនិក ព្រះបាទជយវរ្ម័នទី ៧ គឺជាកេរ្តិ៍ដំណែលដ៏បវរសម្រាប់ប្រជានុរាស្ត្រខ្មែរ ក៏ដូចជាប្រជាជាតិក្នុងភូមិភាគអាស៊ីអាគ្នេយ៍ទាំងមូល នេះដែរ ។ ដូច្នេះហើយ បានជារមណីយដ្ឋានប្រវត្តិសាស្ត្រប្រាង្គ ប្រាសាទដ៏ប្រណីតទាំងឡាយ ក្នុងទឹកដីដ៏មហិមានៃចក្រភព អង្គរក្នុងរជ្ជកាលរបស់ព្រះអង្គ បានធ្វើឲ្យកេរ្តិ៍ឈ្មោះខ្មែរមាន ភាពល្បីរន្ទឺពាសពេញពិភពលោកគួរជាទីមោទនៈ ។ ប៉ុន្តែជា អកុសលក្នុងពេលបច្ចុប្បន្ន ភាពល្បីល្បាញរបស់ព្រះអង្គ បាន នឹងកំពុងត្រូវឆ្លាក់បំបែកជារូបសំណាកពិការព្រះហស្ត និង បែក ព្រះកេសយកទៅតាំងលម្អតាមសួនច្បារ តាមគេហដ្ឋាន ទៅ វិញ ។ ទាំងនេះបានធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំង ដល់លក្ខណៈ ពិសិដ្ឋនៃមហិទ្ធិឫទ្ធិបារមី កិត្តិយស និងតម្លៃសីលធម៌ជាមូលដ្ឋាននៃអ្នកដឹកនាំប្រទេស ដែលបានធ្វើពលិកម្មក្នុងកិច្ចការ បង្រួបបង្រួមជាតិ ឯកភាពជាតិ ការពារអធិបតេយ្យ និងបូរណភាពទឹកដី ។

លោក មឿង សុខ បានបន្ថែមទៀតថា ៖ ដោយមាន ជំនឿទៅលើមហិទ្ធិឫទ្ធិបារមីរបស់ព្រះបាទជយវរ្ម័នទី ៧ លោក បានខិតខំធ្វើការស្រាវជ្រាវយ៉ាងល្អិតល្អន់ ជាមួយបណ្ឌិត មីសែលត្រាណេ នៅតាមតំបន់ផ្សេង ៗ ដូចជានៅក្នុងប្រាសាទ បាជ័យ ស្ថិតនៅក្នុងខេត្តកំពង់ចាម ប្រាសាទព្រះខ័នកំពង់ស្វាយ ខេត្តកំពង់ធំ និងសារមន្ទីរជាតិ និងអន្តរជាតិ ។ ឆ្លងកាត់ តាមការស្រាវជ្រាវនេះ យើងបានរកឃើញនូវរូបសំណាកពិត របស់ព្រះអង្គ ដែលមានលក្ខណៈគ្រប់ទ្រង់ទ្រាយដើម ហើយ បានរួមគំនិតគ្នាកសាងរូបព្រះអង្គឡើងវិញ ទៅតាមទ្រង់ទ្រាយ លក្ខណៈដើម ដើម្បីឲ្យសមទៅនឹងកិត្តិនាម និងការគោរពបូជា ដ៏ខ្ពង់ខ្ពស់ ពីសំណាក់ប្រជាពលរដ្ឋខ្មែរគ្រប់មជ្ឈដ្ឋានទាំងអស់ និង ប្រជាជាតិទូទាំងពិភពលោក ។

ទាក់ទងទៅនឹងរូបសំណាកពិត តាមទ្រង់ទ្រាយដើម របស់ព្រះបាទជ័យវរ្ម័នទី ៧ នោះ លោក មីសែលត្រាណេ អនុប្រធានគណៈកម្មាការជាតិសម្រាប់យូនីស្កូ ដែលជាអ្នកស្រាវជ្រាវលើបញ្ហានោះ បានបំភ្លឺថា ៖ ការដែលហ៊ានសន្និដ្ឋានថា រូប នេះជារូបពិតតាមទ្រង់ទ្រាយដើម គឺបានយកគំរូពីសារមន្ទីរជាតិ ដែលមានរូបមួយកំណាត់ក្រោម បន្ទាប់មកយកគំរូចេញពី ប្រាសាទបាជ័យមួយកំណាត់ខាងលើ ចាប់ពីព្រះហស្តទាំងសង ខាងនៅសល់ពាក់កណ្ដាលខ្លួន ហើយក៏បានយកវត្ថុផាត់ល្អង នៅជីមសាក់ប្រទេសឡាវ ។ ដូច្នេះសំអាងលើឯកសារទាំងនេះ យើងហ៊ានអះអាងថា រូបដែលយើងបង្ហាញទាំងពីរសណ្ឋាននេះ ពិតជារូបពេញលក្ខណៈទ្រង់ទ្រាយដើមពិតប្រាកដមែន ហើយ មានតែពីរសណ្ឋាននេះទេ គឺរូបព្រះអង្គតាំងសមាធិ និងរូបព្រះ អង្គអញ្ជលី ។

(តនៅទំព័រទី ១៦)

## កំណាព្យ

# ខ្ញុំជាប់គុកហើយ

ដោយៈ ធិ.ថាច់ប្រីជាគឿន

ក្នុងគុកគ្មានស្រាគ្មានទាំងស្រី
ដើម្បីចរចារក្លែមនែបនិត្យ
ភ្នែកបើកទាំងទ្វេតែងងឹត
នេះគុកជីវិតឥតជញ្ជាំង ។

ក្នុងគុកគ្មានឧទ្យានកំសាន្ត
គ្មានមិត្តរាប់អានខានហ៊ឺហា
គ្មានទាំងស្រីស្នេហ៍ក្បែរកាយា
រស់ក្នុងអន្ធកាស្តារស្មារតី ។

ក្នុងគុកគ្មានទេកាមតណ្ហា
គ្មានរឿងស្នេហាប្រពន្ធប្តី
គ្មានកូនគ្មានចៅថ្នមបមបី
ជីវិតទីទៃលៃរឿងជាតិ ។

ក្នុងគុកគ្មានទេម្តាយឪពុក
ចិន្តាឱបទុក្ខនឹកផៅញាតិ
ក្នុងស្បែអន្ធកាឲ្យូងចង្អៀត
នឹកឃើញសាសន៍ជាតិបាត់សេរី ។

កាយនៅក្នុងគុកចិត្តនៅក្រៅ
ដង្ហោយស្រែកហៅខ្មែរប្រុសស្រី
ឲ្យស្មោះបរិសុទ្ធចិត្តភក្តី
រំដោះទឹកដីកម្ពុជាក្រោម ។

កាយនៅក្នុងគុកទុក្ខធំធេង
ខ្លាចខ្មែរវង្វេងល្បែងខ្មាំងលោម
លួងឲ្យខ្មែរឈ្លក់វក់ឲ្យរោម
ភ្លេចខ្លួនខ្មែរក្រោមភ្លេចទឹកដី ។

កាយនៅក្នុងគុកទុក្ខគ្រាំគ្រា
ខ្លាចខ្មែរឈ្លោះគ្នាព្រោះសម្តី
ដោយខ្មាំងបញ្ឆោតដោតវក់វី
ឲ្យបែកសាមគ្គីដីបានវា ។

កាយនៅក្នុងគុកទុក្ខរឹតទ្វេ
បារម្ភខ្លាចខ្មែរប្រែចិន្តា
បំណាំគ្នាឯងរែងសង្កា
ចោទដាក់ទោសាថាខ្មែរយួន ។

គុកនេះគុកធំគ្មានជញ្ជាំង
តែមានរបាំងខ្មាំងមាំមួន
គុកនេះគុកចិត្តឋិតក្នុងខ្លួន
គុកនេះគុកសួនបេះដូងខ្ញុំ ៕

# ស្រណោះកម្ពុជាក្រោម

ដោយៈ ចៅតីនិស្សចៅ

ឱ! កម្ពុជាក្រោមដែនដីកំណើត
ទឹកដីល្អឆើតកេរដូនតាខ្ញុំ
រស់តាំងពីតូចរហូតដល់ធំ
ពេលនេះរូបខ្ញុំព្រាត់ទាំងអាល័យ ។

ស្វាយទងជីក្អេងកំណើតកវី
ខ្មែរក្រោមប្រុសស្រីត្រូវយួនប្រល័យ
កាប់សម្លាប់ខ្មែរក្រោមស្ទើររាល់ថ្ងៃ
បនយួនប្រល័យប្លន់ដីដូនតា ។

នឹកឡើងស្រណោះដីក្អេងធ្លាប់យល់
យួនចិត្តពិសពុលគ្មានក្តីមេត្តា
បង្ខំឲ្យខ្មែរព្រាត់ទាំងសោកា
ព្រាត់ទាំងគ្រួសារបងប្អូនគ្និគ្នា ។

ខ្មែរស្នេហាជាតិប្រឆាំងនឹងយួន
ទើបត្រូវភៀសខ្លួនទៅកម្ពុជា
បំរើសហព័ន្ធតាមមាគ៌ា
ឃ្លាតកម្ពុជាក្រោមទាំងទឹកនេត្រា ។

នឹកឡើងស្រណោះដីកម្ពុជាក្រោម
តែរូបប្រុសឆោមសន្យាវិលវិញ
ក្រោយថ្ងៃឯករាជ្យរួចផុតទោម្នេញ
សន្យាវិលវិញកម្ពុជាក្រោមអើយ ៕

# រឿងកម្ពុជាក្រោមគឺជារឿងពិត

ក្នុងនាមខ្ញុំជាកុលបុត្រនៃខ្មែរកម្ពុជាក្រោមមួយរូប ដែលមានដើមកំណើតនៅស្រុកស្វាយទង ខេត្តមាត់ជ្រូក ខ្ញុំមានសេចក្តីត្រេតអរយ៉ាងខ្លាំង ដែលមានវាសនាបានមកចាប់កំណើតកើតនៅលើទឹកដីកម្ពុជាក្រោមដ៏ជាទីស្រលាញ់របស់ខ្ញុំ ។ តែខ្ញុំក៏មានសេចក្តីសោកស្តាយណាស់ដែរ ចំពោះរាល់ទង្វើដែលអាណានិគមយួន បានធ្វើមកលើបងប្អូនខ្មែរកម្ពុជាក្រោមគ្រប់រូប ដែលកំពុងរស់រានមានជីវិតលើដែនដីកំណើតរបស់ខ្លួន ក៏ដូចជាធ្វើមកលើខ្ញុំបាទសព្វថ្ងៃនេះ ។

តាំងពីខ្ញុំបានចាប់កំណើតមក គឺខ្ញុំមានជីវិតរស់នៅលើទឹកដីកម្ពុជាក្រោមតែម្តង រីឯពុកម៉ែ ជីដូនជីតា តាទួតរបស់ខ្ញុំ គឺគាត់មានជីវិតរស់នៅលើទឹកដីកម្ពុជាក្រោមនេះ អស់រាប់សតវត្សរ៍ថ្វាយទៅហើយ ។ តែខ្ញុំពុំដែលបានដឹងសោះ នូវទំព័រប្រវត្តិសាស្ត្រដ៏ជូរចត់របស់ខ្មែរកម្ពុជាក្រោម ដែលត្រូវចោរយួនកុម្មុយនិស្ត បានបំពានមកលើ ។ ដូច្នេះខ្ញុំមានសេចក្តីសោកស្តាយយ៉ាងខ្លាំង ការសោកស្តាយនេះ គឺមិនមានន័យថាស្តីបន្ទោសម្តាយឪពុក ជីដូនជីតារបស់ខ្ញុំទេ គឺសោកស្តាយ នូវរាល់អំពើចោរយួនកុម្មុយនិស្ត ដែលតែងតែតាមបំបិទលាក់បាំងនូវទង្វើរបស់ខ្លួន នូវទំព័រប្រវត្តិសាស្ត្រដ៏ជូរចត់របស់ខ្មែរក្រោម ទើបធ្វើឲ្យកូនចៅខ្មែរក្រោមជំនាន់ក្រោយ ពុំបានយល់ដឹងនូវប្រវត្តិខ្មែរក្រោមទាល់តែសោះ ។

ខ្ញុំចាំមិនភ្លេចនូវថ្ងៃដំបូង ដែលរូបខ្ញុំបានកាន់សៀវភៅដែលមានចំណងជើងថា "ទុក្ខខ្មែរក្រោម" ដែលជាបទនិពន្ធរបស់លោក ថាច់ សិរ និងក្រោយពេលដែលបានស្តាប់នូវចំរៀងស្នេហាជាតិរបស់សហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក គឺបេះដូងរបស់ខ្ញុំញ័ររញ្ជួយតែម្តង ។ ខ្ញុំក៏មានចិត្តពុះកញ្ជ្រោលភ្លាម ប្រៀបបានដូចជាមានម្ជុលរាប់រយចាក់ទម្លុះបេះដូងរបស់ខ្ញុំ ។ គឺធ្វើឲ្យខ្ញុំនឹកស្រណោះអាលោះអាល័យដល់ជាតិ និងបុព្វការីជនដែលពលីកាយថ្វាយជីវិតដើម្បីទឹកដីកម្ពុជាក្រោមភ្លាម ! មិនតែប៉ុណ្ណោះ នៅក្នុងអង្គប្រាណរបស់ខ្ញុំ ហាក់បីដូចជាមានកំដៅភ្លើងរាប់ម៉ឺនអង្សា ពេលដែលបានឃើញយួនចេះតែចង់ជញ្ជក់ឈាម ចង់សម្លាប់ដើម្បីសងសឹកជូនបុព្វការីជនខ្មែរក្រោមដែលបានបាត់បង់ដោយចោរយួននេះឯង ។ ចាប់ពីពេលនោះមកខ្ញុំប្រៀបបានដូចជាមនុស្សចំឡែកម្នាក់ ដែលមានឧត្តមគតិនឹកគិតស្រណោះដល់ជាតិជានិច្ច ។ មិនតែប៉ុណ្ណោះមានពេលខ្លះខ្ញុំភ្លេចហូប មានយប់ខ្លះខ្ញុំភ្លេចដេក ក្នុងចិត្តរបស់ខ្ញុំឈឺចាប់ប្រៀបបានដូចជាមានកាំបិតកាប់ចិញ្ច្រាំ រីឯទឹកភ្នែករបស់ខ្ញុំវិញតែងហូរស្ទើររាល់រាត្រី ។ ហើយតែងតែចោទជាបញ្ហាថា: តើខ្ញុំមានវិបត្តិអ្វី ? ថាគេទៅមានស្នេហាត្រូវព្រាត់ឆ្ងាយគ្នា ឬព្រោះរនាំងស្នេហ៍វណ្ណៈ ចុះចំណែករូបខ្ញុំពុំមានស្នេហាសោះ ហេតុម្តេចក៏មានទុក្ខកង្វល់ខ្វល់ក្នុងចិត្តយ៉ាងនេះ ?!

ពេលនោះហើយ ដែលជាពេលដែលខ្ញុំចាប់ផ្តើមស្ម័គ្រចិត្ត និងពង្រឹងស្មារតីដើម្បីបំរើការឲ្យសហព័ន្ធដោយសម្ងាត់ ។ ទោះបីជាខ្ញុំពុំស្គាល់អ្នកណា ពុំដឹងអ្វីច្បាស់លាស់អំពីសហព័ន្ធ រណៈសិរ្ស សមាគមខ្មែរក្រោមណាក៏ដោយ ក៏ខ្ញុំស្ម័គ្រចិត្តបម្រើដែរ ដោយសារតែខ្ញុំស្រេកឃ្លានខ្លាំងពេក នូវសិទ្ធិសេរីភាព សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯងនៅលើទឹកដីកំណើតរបស់ខ្លួន !

ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ!

បងប្អូនជនរួមឈាមទាំងឡាយជាទីគោរព !

រឿងទឹកដីកម្ពុជាក្រោមត្រូវបាត់បង់នេះ គឺជារឿងពិតដែលមិនអាចប្រកែកបាន ។ ប៉ុន្តែដើម្បីស្វែងរកសិទ្ធិស្វ័យសម្រេចវាសនា សិទ្ធិបញ្ចេញយោបល់ សិទ្ធិជំនឿសាសនា និងសិទ្ធិគោរពតាមប្រពៃណី ទំនៀមទម្លាប់ ដើម្បីរក្សានូវកេរមរតកជាតិ យើងទាំងអស់គ្នាក្នុងនាមជាកុលបុត្រកុលធីតាខ្មែរក្រោមត្រូវតែក្រោកឈរឡើងចាប់ដៃគ្នា ដើម្បីស្តារ និងកសាងឡើងវិញនូវកំលាំងជាតិ ។

ជនរួមឈាមទាំងឡាយជាទីស្នេហា ! ខ្ញុំដឹងច្បាស់ថាសព្វថ្ងៃនេះ នៅក្នុងប្រទេសកម្ពុជាក្រោមយើង គឺមានការរើសអើងពូជសាសន៍យ៉ាងខ្លាំង ! ក្នុងនោះបើសិនជាបងប្អូនជនរួមឈាមមានឧត្តមគតិជាខ្មែរពិតប្រាកដ នោះបងប្អូននឹងបានដឹងបានយល់ អំពីសកម្មភាពរបស់ចោរយួនកុម្មុយនិស្ត សូម្បីតែរូបខ្ញុំ គ្រាន់តែស្នេហ៍ជាតិស្នេហ៍សាសន៍ស្នេហ៍សង្គម ស្នេហ៍វប្បធម៌ឧត្តមម្តាយនឹងបិតា គ្រាន់តែស្នេហ៍អក្សរស្នេហ៍ក្មេង-

ស្នេហ៍ខេមរា គ្រាន់តែស្នេហ៍ស័ព្ទភាសាក៏មានទោសដែរ ! ។ ដូច្នេះ បើសិនជាជនរួមឈាមពុំមានស្មារតីស្រលាញ់ជាតិ និងស្វែងយល់ទេនោះ យើងមិនអាចដឹងថាយួនកំពុងធ្វើអ្វីឡើយ ។ ក្នុងនាមខ្ញុំជាកូនខ្មែរមួយរូប ដែលមានបេះដូងជាខ្មែរ អ្វី ៗ ក៏ជាខ្មែរមិនមែន "ក្បាលយួន ខ្លួនខ្មែរ" ទេនោះ ដែលត្រូវបានយួនគាបសង្កត់បំបិទសិទ្ធិសេរីភាពនោះ ។ ខ្ញុំសូមអំពាវនាវដល់ជនរួមឈាមទាំងឡាយ មិនថាតែ បុរស-ស្ត្រី ឬ និស្សិតបញ្ញវ័ន្តទេ គឺឲ្យតែជាខ្មែរ គឺយើងត្រូវមានស្មារតីស្រលាញ់ជាតិមាតុភូមិកម្ពុជាក្រោមយើងជានិច្ច ។ ហើយថ្វីត្បិតតែអំរែកសោកនាដ-កម្មរបស់ដូនតាខ្មែរក្រោម បានកប់បាត់ទៅក្នុងបាតជំរៅអតីតកាលអស់រាប់សតវត្សរ៍ទៅហើយក៏ដោយ ក៏គ្មានរនាំងច្បាប់ណាមួយអាចឃាំង ឬហាមឃាត់កូនចៅខ្មែរក្រោមជំនាន់ក្រោយមិនឲ្យដឹងជនល្មើសចោរព្រៃបិសាចយួន ឈ្លានពានប្ល័ន់ទឹកដីនិងជិះជាន់ រំលោភសិទ្ធិបងប្អូនរួមជាតិខ្មែរក្រោមបានឡើយ ។ តើនរណា ដែលមិនចេះស្រលាញ់ដែនដីកំណើតរបស់ខ្លួននោះ ? តើនរណាដែលមិនចេះឈឺចាប់ ពេលដែលដឹងថាទឹកដីដ៏សែនស្រលាញ់របស់ខ្លួន ត្រូវធ្លាក់ក្នុងកណ្តាប់ដៃសាសន៍ឯទៀតដោយគ្មានហេតុផលបែបនេះ ?

ខ្ញុំចាំមិនភ្លេច កាលដែលខ្ញុំជានិស្សិតមួយរូបដែលសិក្សានៅសាលាជនជាតិអន្តេវាសិកដ្ឋានខេត្តមាត់ជ្រូក ។ ថ្វីតែក្បាល និងបេះដូងរបស់ខ្ញុំជាខ្មែរពិតប្រាកដ តែខ្ញុំត្រូវយួនបញ្ចូលមនោគមន៍វិជ្ជាស្ទើរឆ្កួតទៅហើយ ។ គឺយួនឲ្យរៀនតែអក្សរសាស្ត្រយួន ប្រវត្តិសាស្ត្រយួន និងមនោគមន៍វិជ្ជាជាច្រើនដែលមានគំនិតកែប្រែខ្មែរឲ្យក្លាយជាយួន ដើម្បីបំបាត់ភ័ស្តុតាងបំបាត់ពូជសាសន៍ខ្មែរក្រោម ។

មិនត្រឹមតែប៉ុណ្ណោះ យួនបានឲ្យឈ្មោះខ្មែរក្រោមយើងមួយយ៉ាងចំឡែកដែលភាសាយួនហៅថា "ង៉ើយយ៉ឹងតុត"(Nguoi Dan Toc) ពាក្យនេះបានន័យថា "មនុស្សជនជាតិ" ។ សូមព្រះ-តេជគុណព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជនរួមឈាមស្តាប់មើលទៅ ! ខ្មែរដែលមានកំណើតដើម មានប្រពៃណីវប្បធម៌ទំនៀមទំលាប់ និងមានវត្តអារាមពាសពេញដែនដីកម្ពុជាក្រោមដែលនិយាយតែភាសាខ្មែរនោះបែរជាចោរយួនហៅថា ជា "មនុស្សជនជាតិ" ទៅវិញ ! នេះហើយ គឺជាការគៃបន្លំ និងបំបាត់អត្តសញ្ញាណជាតិខ្មែរក្រោមយើងទាំងអស់គ្នា ។ មិនតែប៉ុណ្ណោះ ខ្ញុំចាំបានថា កាលនៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០០៣ ក្នុងសាលារៀនខ្ញុំដែលជាសាលាជនជាតិអន្តេវាសិកដ្ឋាន ខេត្តមាត់ជ្រូកសំរាប់កូនខ្មែរ ដែលមានសាសន៍យួនចូលរៀនលាយឡំដែរនោះ គឺមានគ្រូយួនម្នាក់ឈ្មោះ ប៊ួយវ៉ាំងហាន់ (Bui Van Hanh) ដែលបង្រៀនវិញ្ញាសាប្រវត្តិសាស្ត្រ បានអះអាង និងគៃបន្លំនូវទំព័រប្រវត្តិសាស្ត្រថាៈ ខ្មែរក្រោម គឺជាជនជាតិភាគតិច ដែលពុំមានអត្តសញ្ញាណពិតប្រាកដឡើយ ។ ហើយយកទំនៀមទំលាប់របស់គេមកធ្វើជារបស់ខ្លួនតែប៉ុណ្ណោះ ! ខ្ញុំសូមសួរជនរួមឈាមដោយស្មោះថា បើជនរួមឈាមមានឧត្តមគតិស្នេហាជាតិ និងដឹងនូវរឿងរ៉ាវប្រវត្តិសាស្ត្រពិត ៗ ហើយពេលដែលបានឮយួននិយាយដូច្នោះ តើជនរួមឈាមមានអារម្មណ៍បែបណា ? នោះហើយជាបញ្ហា ហើយក៏ជាថ្ងៃនោះដែរ ដែលទឹកភ្នែករបស់ខ្ញុំស្រាប់តែហូរស្រក់មកឯង ៗ នូវក្នុងថ្នាក់រៀន ដោយពុំបានដឹងខ្លួនទាល់តែសោះ ក្រោយពេលដែលបានឮសិស្សនិស្សិតខ្មែរ ៣២ នាក់ក្នុងចំណោម ៣៣ នាក់យល់ស្របតាមគ្រូយួននោះ ។ ក៏ដោយសារសិស្សនិស្សិតទាំងនោះ ត្រូវយួនបញ្ចូលមនោគមន៍វិជ្ជាដែរ ។

ជនរួមឈាម និងមិត្តនិស្សិតខ្មែរក្រោមទាំងឡាយជាទីគោរព !

សូមជនរួមឈាមត្រិះរិះឲ្យច្បាស់ និងសម្លឹងឲ្យឆ្ងាយ បើពិតដូច្នោះមែន ចុះហេតុដូចម្តេចក៏ភាគខាងត្បូងនៃប្រទេសវៀតណាម មានវត្តខ្មែរជាង ៦០០ និងប្រជាជនខ្មែររាប់លាននាក់? ហើយបើយើងសុំច្បាប់អនុញ្ញាតិសាងសង់វត្ត តើយួនអនុ-ញ្ញាតិដែរឬទេ? កុំថាឡើយសាងសង់ សូម្បីតែជួសជុល ក៏យួនពុំព្រមអនុញ្ញាតិផង! រីឯប្រពៃណីវប្បធម៌នោះ គឺកាន់តែខុសឆ្ងាយពីជាតិសាសន៍យួនទៅទៀត ។ នេះហើយ គឺជាកេរដូនតាយើងបន្សល់ទុកឲ្យយើងគ្រប់រូប ហើយក៏អាចបញ្ជាក់បានដែរថា យើង គឺជាជនជាតិដើមនៃដែនដីកម្ពុជាក្រោមដែលមានដើមកំណើត កើតនៅលើទឹកដីរបស់យើងទាំងអស់គ្នាជាយូរលង់ណាស់មកហើយ ។ មូលហេតុដែលកុលបុត្រនៃខ្មែរក្រោមពុំបានដឹង នូវប្រវត្តិដើមខ្លួននោះ ក៏ព្រោះតែយួនបង្វែងដាន និងគៃបន្លំទំព័រប្រវត្តិសាស្ត្រ ថែមទាំងបានត្រូវបញ្ចូលមនោគមន៍វិជ្ជាផងដែរ ។ ដោយឡែក គឺបងប្អូនជនរួមឈាម និស្សិតបញ្ញវ័ន្តពុំបានរៀននូវអក្សរសាស្ត្រ ប្រវត្តិសាស្ត្រជាតិនៃខ្មែរកម្ពុជាក្រោមផង ។ ដោយសារតែយួនខ្ទប់ជនរួមឈាម មិត្តនិស្សិតបានដឹងនូវទង្វើដ៏ព្រៃផ្សៃរបស់ពួកវា ។

# វេទិកាគំនិតជាតិ

មកដល់សព្វថ្ងៃនេះ យួនពុំបានផ្តល់សិទ្ធិគ្រប់គ្រាន់ដល់យើងឡើយ សូម្បីតែការប្រើប្រាស់អ៊ីនធើណែត របស់បងប្អូនមិត្តនិស្សិត ជួបជុំសម្តែងមតិ ការអាន ការមើល ស្តាប់នូវចំរៀងរបស់សហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក និង ព្រឹត្តិបត្រកម្ពុជាក្រោម ក៏យួនពុំអនុញ្ញាតិដែរ ថែមទាំងតាមចាប់អ្នកស្រាវជ្រាវ អ្នកផ្សព្វផ្សាយ នូវឯកសារអ្វីដែលទាក់ទិននឹងអក្សរសាស្ត្រខ្មែរទៀតផង ។ នេះហើយ គឺជាការបំបិទសិទ្ធិ បំពានលើសិទ្ធិមនុស្ស ដែលអង្គការសហប្រជាជាតិបានចែងមក ។

តែទោះជាយ៉ាងណាក្តី ខ្ញុំយកបេះដូង និងចិត្តស្មោះសរបស់ខ្ញុំ សូមអំពាវនាវដល់សន្តានចិត្តនៃជនរួមឈាមខ្មែរក្រោមថា សូមបងប្អូនទាំងឡាយកុំតក់ស្លុត និងភិតភ័យនូវទង្វើទាំងនេះឲ្យសោះ គឺយើងត្រូវតែសាមគ្គីគ្នាជានិច្ច ព្រោះសព្វថ្ងៃនេះយើងមានសហព័ន្ធជាអាវុធ ដែលជាអ្នកស្វែងរកសិទ្ធិស្វ័យសម្រេចវាសនាខ្លួនដោយខ្លួនឯងជូនបងប្អូន ។ តែបើចង់បានដូច្នោះ លុះត្រាតែយើងជាកុលបុត្រខ្មែរដែលកំពុងរស់នៅលើទឹកដីកម្ពុជាក្រោមត្រូវតែភ្ញាក់ខ្លួន និងក្រោកឈរឡើងដើម្បីប្តឹងទៅអន្តរជាតិ ពីបទចោរយួនឈ្លានពានលេបយកទឹកដីរបស់គេមកធ្វើជារបស់ខ្លួន ។ មិនតែប៉ុណ្ណោះ យើងមិនត្រូវជឿតាមពាក្យញុះញង់ ឃោសនារបស់ចោរយួនទៀតឡើយ ព្រោះដោយសារតែពួកវា ទើបយើងទាំងអស់គ្នាត្រូវបែកបាក់សាមគ្គី ។ កាលពីមុន យើងពុំមាននរណាធ្វើជានាវាសម្រាប់ចម្លងយើងឡើយ តែសព្វថ្ងៃនេះ យើងមានសហព័ន្ធជាអ្នកត្រួសត្រាយនាំមុខ ដែលយើងទាំងអស់គ្នាជាកូនខ្មែរត្រូវមានកាតព្វកិច្ច ។ ហើយបើមានហេតុការណ៍អ្វីមួយកើតឡើង ដូចជាកាប់សម្លាប់ចាប់និស្សិត ឬ ព្រះសង្ឃដាក់ពន្ធនាគារ ចូរបងប្អូនជនរួមឈាមត្រូវក្លាហានបញ្ចេញយោបល់ និងត្រូវផ្តល់ពត៌មានដែលមានអាស័យដ្ឋានតាមគេហទំព័រដូចខាងក្រោមនេះ ឬក៏ផ្តល់ពត៌ដល់អង្គការសិទ្ធិមនុស្ស ។ល។

បងប្អូនជនរួមឈាមទាំងឡាយជាទីស្នេហា! យើងទាំងអស់គ្នា ជាកូនខ្មែរជាពូជខ្មែរអង្គរគឺក្លាហានណាស់ ទឹកដីកម្ពុជាក្រោមរួមមាន ២១ ខេត្ត និងផ្ទៃដី ៦៨៦០០ គីឡូម៉ែត្រក្រឡា ដែលត្រូវចោរយួនប្លន់ ហើយប្រែជាកាសាយួននោះ គឺជារបស់យើងពិត ៗ ឥតប្រកែកឡើយ ។ ដូច្នេះយើងគប្បីស្វែងរកសិទ្ធិសំរេចវាសនាខ្លួនដោយខ្លួនឯងលើទឹកដីរបស់យើង វាប្រសើរជាជាងបណ្តោយឲ្យចោរយួនគាបសង្កត់ជិះជាន់រាល់ថ្ងៃ ។ តែស្ថានភាពនៅកម្ពុជាក្រោមសព្វថ្ងៃនេះ គឺពោរពេញទៅដោយការរើសអើង និងបំបាត់សិទ្ធិមនុស្ស ។

ដូច្នេះ ក្នុងនាមខ្ញុំដែលមានឈាមជ័រ បេះដូងជាខ្មែរក្រោម សូមរំឭកនូវស្មារតីរបស់ជនរួមឈាមទាំងឡាយឡើងវិញ គឺសូមឲ្យអ្នកទាំងឡាយ ត្រូវក្លាហាន និង ពង្រឹងស្មារតី ដើម្បីកសាងមាតុភូមិកម្ពុជាក្រោមយើងទាំងអស់គ្នាឡើងវិញ ។ ហើយយើងគម្បីជឿស្តាប់ តាមពាក្យញុះញង់របស់ចោរយួនទៀតឲ្យសោះ ។ យើងទាំងអស់គ្នាត្រូវខំសិក្សា និងត្រូវភ្ញាក់ខ្លួន ដើម្បីជាជំហរជម្រុញនាវាសហព័ន្ធខ្មែរកម្ពុជាក្រោមឆ្ពោះទៅដល់ត្រើយសន្តិភាព ។ ព្រោះយើងជាទំពាំងស្នងឫស្សី យើងមិនត្រូវធ្វើឲ្យមេឫស្សីអស់សង្ឃឹមឡើយ ៕

"ទំពាំងថ្មី ចំណិថ្មី"

**ដោយ ចៅមុនីខេមរា**




**-វិទ្យុសំឡេងកម្ពុជាក្រោម** ជាសំឡេងរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ផ្សាយចេញពីក្រុងវ៉ាស៊ីនតោន រដ្ឋធានីនៃសហរដ្ឋអាមេរិក សម្រាប់បម្រើដល់ប្រិយមិត្តអ្នកនិយមស្តាប់ការផ្សាយរបស់វិទ្យុយើងខ្ញុំ ។

**-កម្មវិធីផ្សាយ** ៖ ផ្សាយក្នុងមួយសប្តាហ៍ម្តង រៀងរាល់ថ្ងៃអង្គារ ចាប់ពីម៉ោង ៩ ដល់ម៉ោង ១០ យប់ ម៉ោងនៅកម្ពុជាក្រោម តាមកម្ពស់រលកជាតុអាកាសខ្លី ១៥.៦៩០ គីឡូហឺត ។

-ប្រិយមិត្ត ក៏អាចបើកស្តាប់បានគ្រប់ពេល តាមរយៈគេហទំព័រ www.khmerkrom.org/radio ។

*(តមកពីទំព័រទី ១១)*

លោក មីសែលត្រាណោ បានបន្តថា ៖ នេះជាលើកទីមួយហើយ ដែលយើងហ៊ានសន្និដ្ឋានយ៉ាងពិតប្រាកដថា ៖ រូបនេះពិតជារូបដែលមានលក្ខណៈទៅតាមទ្រង់ទ្រាយដើម ព្រោះគេនៅមានមន្ទិលសង្ស័យនៅឡើយថា ៖ រូបនោះមានសណ្ឋានយ៉ាងដូចម្ដេច រូបនេះជាភ័ស្តុតាងជាក់ស្ដែងឥតប្រកែកបាន ហើយយើងជឿដោយស្មោះ ព្រោះយើងជាអ្នកស្រាវជ្រាវ ពិតមានលក្ខណៈប្រវត្តិសាស្ត្រ ។

ព្រះបញ្ញាសោភ័ណ គៀត ច័ន្ទធុច ទីប្រឹក្សាផ្ទាល់សម្ដេចព្រះសុមេធាធិបតី ទេព វង្ស និងជាព្រះគ្រូចៅអធិការវត្តជោតញ្ញាណ ក្រុងព្រះសីហនុ ធ្លាប់បានមានសង្ឃដីកាអំពាវនាវឲ្យពុទ្ធបរិស័ទទាំងអស់សង់រូបសំណាកព្រះបាទជយវរ្ម័នទី ៧ ឲ្យគ្រប់លក្ខណៈទ្រង់ទ្រាយដើម ទើបធ្វើឲ្យប្រទេសមានសន្តិភាព ។ ការកសាងសង់រូបព្រះបាទជ័យវរ្ម័នទី ៧ ដោយពិការព្រះហស្តទាំងសងខាង មានន័យស្មើនឹងការប្រមាថចំពោះព្រះមហាវរក្សត្រសម័យចក្រភពអង្គរ ៕

*ដកស្រង់ចេញពីសារព័ត៌មាន* ***កោះសន្តិភាព***

## សេចក្ដីកែតម្រូវ

ក្នុងព្រឹត្តិបត្រ កម្ពុជាក្រោម លេខ ២១ ឆ្នាំទី ២ ត្រង់ទំព័រទី ១៣ បន្ទាត់ខាងក្រោមបំផុត បានសរសេរថា *"តពីព្រះអង្គជ័យជេដ្ឋាទី ២"* សូមកែមកថា *"តពីព្រះបាទជ័យវរ្ម័នទី ៧"* ។ សូមអភ័យទោសពីសំណាក់ប្រិយមិត្តអ្នកអាន ចំពោះកំហុសឆ្គងដោយអចេតនានេះ ។

សូមអរព្រះគុណ និង អរគុណ



ព្រះអង្គម្ចាស់ក្សត្រីស៊ីសុវត្ថិ នារីមុនីពង្ស យាងចូលរួមមហាសន្និបាតសាមញ្ញនៃសម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម